**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០២៤.២៩៩ ប្រ.ក

# ប្រកាស
## ស្តីពី
## ហានិភ័យទីផ្សារសម្រាប់អនុបាតសាពគ្រប់គ្រាន់នៃដើមទុន របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី ការតែងតាំង លោកជំទាវ **ជា សិរី** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់របស់ធនាគារជាតិនៃកម្ពុជា។

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងផ្តល់វិធានសម្រាប់វាស់វែងហានិភ័យទីផ្សារក្នុងការអនុវត្តក្របខ័ណ្ឌសាពគ្រប់គ្រាន់នៃដើមទុន។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា តទៅនេះហៅថា "គ្រឹះស្ថាន"។

គ្រឹះស្ថានត្រូវគណនាទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យទីផ្សារ ទាំងកម្រិតគ្រឹះស្ថាន និងកម្រិតគួបសរុប ប្រសិនបើមាន។

**ប្រការ ៣.- កម្រិតកំណត់កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារ**

គ្រឹះស្ថានត្រូវគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារក្នុងករណី៖

- ប៉ូស៊ីសិនបញ្ជិកាជួញដូរនៃគ្រប់រូបិយបណ្ណដែលសមមូលជាប្រាក់រៀល គិតជាមធ្យមក្នុងរយៈពេល៦ (ប្រាំមួយ) ខែ មានចំនួនចាប់ពី ៤០ (សែសិប) ប៊ីលានរៀល ឡើងទៅ ឬ
- ប៉ូស៊ីសិនបញ្ជិកាជួញដូរនៃគ្រប់រូបិយបណ្ណដែលសមមូលជាប្រាក់រៀល ធៀបនឹងទ្រព្យសកម្មសរុប គិតជាមធ្យមក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ មានចំនួនចាប់ពី ៥ (ប្រាំ) ភាគរយ ឡើងទៅ។

ការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារនៅក្នុងប្រកាសនេះ អនុវត្តចំពោះតែហានិភ័យអត្រាការប្រាក់ ហានិភ័យមូលបត្រកម្មសិទ្ធិ និងហានិភ័យអត្រាប្តូរប្រាក់ប៉ុណ្ណោះ។

ក្នុងករណីប៉ូស៊ីសិនបញ្ជិកាជួញដូរនៃគ្រប់រូបិយបណ្ណដែលសមមូលជាប្រាក់រៀល គិតជាមធ្យមក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ មានតិចជាងកម្រិតកំណត់ខាងលើ គ្រឹះស្ថានត្រូវអនុវត្តកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារចំពោះតែហានិភ័យអត្រាប្តូរប្រាក់ប៉ុណ្ណោះ។

គំរូរបាយការណ៍ ស្តីពី ប៉ូស៊ីសិនបញ្ជិកាជួញដូរ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យបច្ចេកទេសមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ហានិភ័យទីផ្សារ (Market risk)** សំដៅដល់ហានិភ័យនៃការខាតបង់ចំពោះខ្ទង់ក្នុង និងក្រៅតារាងតុល្យការ ដែលបណ្តាលមកពីការប្រែប្រួលថ្លៃនៅលើទីផ្សារ។
- **បញ្ជិកាជួញដូរ (Trading book)** សំដៅដល់កិច្ចបញ្ជិកាដែលគ្រឹះស្ថានប្រើប្រាស់សម្រាប់កត់ត្រាឧបករណ៍ហិរញ្ញវត្ថុដែលគ្រឹះស្ថានមានបំណងកាន់កាប់សម្រាប់ជួញដូរ ឬការពារហានិភ័យនៃឧបករណ៍ផ្សេងទៀតនៅក្នុងបញ្ជិកាជួញដូរ។
- **ហានិភ័យបេស៊ីស (Basis risk)** សំដៅដល់ហានិភ័យដែលកើតឡើងដោយសារថ្លៃនៃឧបករណ៍ហិរញ្ញវត្ថុនិងថ្លៃនៃឧបករណ៍ការពារហានិភ័យនៅក្នុងយុទ្ធសាស្ត្រការពារថ្លៃ ប្រែប្រួលមិនស្របគ្នាទាំងស្រុង ដែលការណ៍នេះកាត់បន្ថយប្រសិទ្ធភាពនៃយុទ្ធសាស្ត្រការពារថ្លៃ។
- **ហានិភ័យខ្សែកោងទិន្នផល (Yield curve risk)** សំដៅដល់ហានិភ័យដែលកើតឡើងដោយសារការប្រែប្រួលនៃអត្រាការប្រាក់ក្នុងទីផ្សារ បញ្ច្រាសពីរចនាសម្ព័ន្ធនៃសំពៀតមូលបត្របំណុលដែលគ្រឹះស្ថានកាន់កាប់។

- **កាតព្វកិច្ចដើមទុន (Capital requirement)** សំដៅដល់បរិមាណដើមទុនដែលគ្រឹះស្ថានត្រូវរក្សាទុកគិតជាភាគរយទៅតាមប្រភេទអ៊ិចស្ប៉ូស៊ើដែលគ្រឹះស្ថានប្រឈមនឹងហានិភ័យទីផ្សារ។
- **មូលបត្រ (Security)** សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបញ្ជាក់ពីសិទ្ធិកាន់កាប់នៅក្នុងក្រុមហ៊ុនមួយ ឬភាពជាម្ចាស់បំណុល ដូចជា មូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទ។
- **មូលបត្របំណុល (Debt security)** សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលអនុញ្ញាតឱ្យអ្នកបោះផ្សាយមូលបត្រខ្ចីប្រាក់ពីវិនិយោគិនដោយសន្យាសងត្រឡប់ទាំងប្រាក់ដើម និងការប្រាក់ ហើយឧបករណ៍ហិរញ្ញវត្ថុនេះអាចជួញដូរបាននៅលើទីផ្សារមុនឥណប្រតិទាន។
- **មូលបត្របំណុលអាចប្តូរបាន (Convertible debt security)** សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុជាបំណុលដែលអាចប្តូរជាភាគហ៊ុនទូទៅរបស់អ្នកបោះផ្សាយ តាមតម្លៃដែលបានកំណត់ជាមុន។
- **ឧបករណ៍និស្សន្ទ (Derivative)** សំដៅដល់កិច្ចសន្យារវាងភាគីពីរឬច្រើន ដែលតម្លៃឧបករណ៍និស្សន្ទ ត្រូវផ្អែកលើតម្លៃទ្រព្យសកម្មសាមី មួយឬច្រើន។
- **ភ្នាក់ងារចាត់ថ្នាក់ឥណទាន (External Credit Assessment Institution - ECAI)** សំដៅដល់ភ្នាក់ងារចាត់ថ្នាក់ឥណទានដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។
- **ឧបករណ៍ហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងអត្រាការប្រាក់ (Interest rate related instrument)** សំដៅដល់ឧបករណ៍ទាំងឡាយណាដែលប្រែប្រួលថ្លៃ នៅពេលអត្រាការប្រាក់ប្រែប្រួល។
- **ឡុងប៉ូស៊ីសិន (Long position)** សំដៅដល់ប៉ូស៊ីសិនដែលគ្រឹះស្ថានជាអ្នកទិញសុទ្ធ (Net buyer) នៃទ្រព្យសកម្ម។
- **សតប៉ូស៊ីសិន (Short position)** សំដៅដល់ប៉ូស៊ីសិនដែលគ្រឹះស្ថានជាអ្នកលក់សុទ្ធ (Net seller) នៃទ្រព្យសកម្ម។
- **ណេគសតសែលលីង (Naked short selling)** សំដៅដល់ការធ្វើប្រតិបត្តិការលក់ឧបករណ៍ហិរញ្ញវត្ថុក្នុងបញ្ជិកាជួញដូរដែលគ្រឹះស្ថានមិនកាន់កាប់ និងមិនបានខ្ចីទុកជាមុន។
- **ប៉ូស៊ីសិនផ្គូផ្គង (Matched position)** សំដៅដល់តម្លៃដាច់ខាតតូចជាង ដែលបានពីការប្រៀបធៀបរវាងឡុងប៉ូស៊ីសិន និងសតប៉ូស៊ីសិនដើម្បីគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាការប្រាក់ទីផ្សារទូទៅ។ ឧទាហរណ៍៖ ប្រសិនបើគ្រឹះស្ថានមានឡុងប៉ូស៊ីសិន ១.២០០ លានរៀល និងសតប៉ូស៊ីសិន ៧០០ លានរៀល នោះប៉ូស៊ីសិនផ្គូផ្គងមានចំនួន ៧០០ លានរៀល។
- **ការកាត់កងប៉ូស៊ីសិន (Position offsetting)** សំដៅដល់ដំណើរការនៃការកាត់កងឡុងប៉ូស៊ីសិន និងសតប៉ូស៊ីសិន នៅក្នុងប្រភេទហានិភ័យដូចគ្នា (ហានិភ័យអត្រាការប្រាក់ ហានិភ័យមូលបត្រកម្មសិទ្ធិ ឬហានិភ័យអត្រាប្តូរប្រាក់)។

- **ម៉ាកធូម៉ាខេត (Mark to market)** សំដៅដល់ការប្រែប្រួលជាប្រចាំថ្ងៃនូវតម្លៃទីផ្សារនៃមូលបត្រ ឬឧបករណ៍និស្សន្ទ ដោយផ្អែកលើតម្លៃដែលបានចេញផ្សាយជាសាធារណៈ (ដោយទីផ្សារមូលបត្រ ឬ Market-makers)។
- **ណូសិនណលប៉ូស៊ីសិន (Notional position)** សំដៅដល់ប៉ូស៊ីសិនដែលមានតម្លៃសមមូលនឹងទ្រព្យសកម្មសាមីរបស់ឧបករណ៍និស្សន្ទ ហើយត្រូវបានកំណត់ដោយថ្លៃចារឹក ឬថ្លៃទីផ្សារ។
- **អប់ហ្សិន (Option)** សំដៅដល់កិច្ចសន្យាឧបករណ៍និស្សន្ទដែលផ្តល់សិទ្ធិ (មិនមែនជាកាតព្វកិច្ច) ក្នុងការទិញ ឬលក់មូលបត្រ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតក្នុងតម្លៃដែលបានព្រមព្រៀងជាមុន (Strike-price) ក្នុងអំឡុងពេល ឬកាលបរិច្ឆេទជាក់លាក់ណាមួយ (កាលបរិច្ឆេទអនុវត្តកិច្ចសន្យា)។
- **កិច្ចសន្យារីប៉ូ (Repo agreement)** សំដៅដល់ប្រតិបត្តិការដែលភាគីមួយលក់មូលបត្រឱ្យភាគីមួយទៀត ដោយសន្យាទិញមូលបត្រនោះត្រឡប់មកវិញ នាកាលបរិច្ឆេទជាក់លាក់ណាមួយទៅតាមតម្លៃដែលបានកំណត់ទុកមុន។
- **កិច្ចសន្យារីវើសរីប៉ូ (Reverse-repo agreement)** សំដៅដល់ប្រតិបត្តិការដែលភាគីមួយទិញមូលបត្រពីភាគីមួយទៀតដោយសន្យាលក់មូលបត្រនោះត្រឡប់មកវិញ នាកាលបរិច្ឆេទជាក់លាក់ណាមួយទៅតាមតម្លៃដែលបានកំណត់ទុកមុន។
- **យុទ្ធសាស្ត្រអាប៊ីត្រាច (Arbitrage strategy)** សំដៅដល់យុទ្ធសាស្ត្រកេងយកចំណេញលើភាពខុសគ្នានៃថ្លៃនៅក្នុងទីផ្សារ។
- **ទ្រព្យសកម្មសាមី (Underlying asset)** សំដៅដល់ទ្រព្យសកម្មដែលអាចជាមូលបត្របំណុលសាមី មូលបត្រកម្មសិទ្ធិសាមី អាត្រាការប្រាក់សាមី រូបិយបណ្ណសាមី ជាដើម ដែលតម្លៃទ្រព្យសកម្មនោះជាកត្តាកំណត់ថ្លៃនៃឧបករណ៍និស្សន្ទ។

## ប្រការ ៥.- សកម្មភាពជួញដូរដែលត្រូវបានលើកលែង

កាតព្វកិច្ចដើមទុនសម្រាប់សកម្មភាពជួញដូរមួយចំនួនត្រូវបានលើកលែងដូចខាងក្រោម៖

- ការកាន់កាប់ប៉ូស៊ីសិនជាខុម៉ូឌីធី (Commodity position) និង
- ការអនុវត្តយុទ្ធសាស្ត្រអាប៊ីត្រាច (Arbitrage strategy) ចំពោះមូលបត្រកម្មសិទ្ធិ។

ធនាគារជាតិនៃកម្ពុជាអាចនឹងកំណត់កាតព្វកិច្ចដើមទុនចំពោះសកម្មភាពខាងលើ ឬសកម្មភាពជួញដូរផ្សេងទៀត នៅក្នុងបទប្បញ្ញត្តិដោយឡែក តាមការចាំបាច់។

## ប្រការ ៦.- សកម្មភាពជួញដូរត្រូវបានហាមឃាត់

គ្រឹះស្ថានត្រូវជួញដូរឧបករណ៍ហិរញ្ញវត្ថុណាដែលមានក្នុងទីផ្សារមូលបត្រផ្លូវការ ឬនៅទីផ្សាររំលងបញ្ជរប៉ុណ្ណោះ ដែលក្នុងនោះសកម្មភាពជួញដូរឧបករណ៍មួយចំនួនត្រូវបានហាមឃាត់ដូចខាងក្រោម៖

- ការលក់អប់ហ្សិន និង
- ការធ្វើណេគសតសែលលីង។

h

# ជំពូកទី ២

# អភិបាលកិច្ច និងការវាយតម្លៃដោយប្រុងប្រយ័ត្ន

## ប្រការ ៧.- ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់

ក្រុមប្រឹក្សាភិបាលត្រូវបង្កើត អនុម័ត និងពិនិត្យឡើងវិញជាប្រចាំលើក្របខ័ណ្ឌគ្រប់គ្រងហានិភ័យទីផ្សារ។ ក្រុមប្រឹក្សាភិបាលត្រូវធានាថា គោលនយោបាយ ដំណើរការ និងប្រព័ន្ធ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពដើម្បី កំណត់ វាយតម្លៃ តាមដាន គ្រប់គ្រង និងដោះស្រាយបញ្ហាហានិភ័យទីផ្សារក្រោមការទទួលខុសត្រូវដោយផ្ទាល់របស់គណៈគ្រប់គ្រងជាន់ខ្ពស់។ ក្រុមប្រឹក្សាភិបាលត្រូវកំណត់និងអនុម័តរីសអាប់ភែថាយដែលគ្រឹះស្ថានមានបំណងទទួលយកសម្រាប់ហានិភ័យទីផ្សារដែលបញ្ជាក់អំពីចរិតលក្ខណៈ ប្រភេទ និងកម្រិតហានិភ័យទីផ្សារ។

គណៈគ្រប់គ្រងជាន់ខ្ពស់ ត្រូវធានាថា គ្រឹះស្ថានមាននីតិវិធី និងប្រព័ន្ធបច្ចេកទេស ដែលអាចកំណត់ វាស់វែង តាមដាន រាយការណ៍ គ្រប់គ្រង ឬកាត់បន្ថយហានិភ័យទីផ្សារ ស្របតាមគោលនយោបាយដែលក្រុមប្រឹក្សាភិបាលបានអនុម័ត។ គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវធានាថា គ្រឹះស្ថានបានបែងចែកមុខងារភារកិច្ចឱ្យបានត្រឹមត្រូវរវាងអ្នកទទួលបន្ទុកលើប្រតិបត្តិការទីផ្សារ អ្នកវាយតម្លៃ អ្នកគ្រប់គ្រងហានិភ័យ អ្នកចុះកិច្ចបញ្ជិកា និងអ្នកត្រួតពិនិត្យ។

## ប្រការ ៨.- ការគ្រប់គ្រងហានិភ័យ

គ្រឹះស្ថានត្រូវគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារ ចំពោះរាល់ឧបករណ៍ដែលអាចមានហានិភ័យអត្រាការប្រាក់ ហានិភ័យមូលបត្រកម្មសិទ្ធិ និងហានិភ័យអត្រាប្តូរប្រាក់នាកាលបរិច្ឆេទដែលប្រតិបត្តិការនោះកើតឡើង។

គ្រឹះស្ថានត្រូវគ្រប់គ្រងហានិភ័យទីផ្សារដោយបំពេញកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារគ្រប់ពេលវេលា រួមទាំងកាតព្វកិច្ចដើមទុននាចុងថ្ងៃធ្វើការ។ គ្រឹះស្ថានត្រូវធានាថា សកម្មភាពជួញដូរ ត្រូវស្ថិតក្នុងកម្រិតកំណត់ហានិភ័យទីផ្សារ រួមទាំងកម្រិតកំណត់ប្រតិបត្តិការក្នុងថ្ងៃ។

ក្នុងករណីកាតព្វកិច្ចដើមទុនរបស់គ្រឹះស្ថានមិនគ្រប់គ្រាន់តាមកម្រិតកំណត់ក្នុងពេលណាមួយ គ្រឹះស្ថានត្រូវចាត់វិធានការបន្ទាន់ក្នុងការបំពេញកាតព្វកិច្ចនោះ។

## ប្រការ ៩.- វិធីសាស្ត្រវាយតម្លៃ

គ្រឹះស្ថានត្រូវធ្វើម៉ាកធូម៉ាខេតចំពោះរាល់ប៉ូស៊ីសិនរៀងរាល់ថ្ងៃតាមតម្លៃទីផ្សារចុងថ្ងៃដែលបានពីប្រភពឯករាជ្យដើម្បីទទួលបាននូវតម្លៃប៉ូស៊ីសិន។ ក្នុងករណីគ្រឹះស្ថានមិនអាចធ្វើម៉ាកធូម៉ាខេតបាន គ្រឹះស្ថានត្រូវប្រើប្រាស់តម្លៃចារឹក។

គ្រឹះស្ថានត្រូវបង្កើត និងរក្សាប្រព័ន្ធគ្រប់គ្រងដែលមានប្រសិទ្ធភាព ដើម្បីធានាថាការវាយតម្លៃនោះ មានលក្ខណៈប្រុងប្រយ័ត្ននិងអាចជឿទុកចិត្តបាន។ ប្រព័ន្ធគ្រប់គ្រងនេះត្រូវរួមបញ្ចូលៈ

- គោលនយោបាយនិងនីតិវិធីវាយតម្លៃ ដោយកំណត់ច្បាស់លាស់អំពី ១/- ការទទួលខុសត្រូវរបស់ផ្នែកផ្សេងៗដែលពាក់ព័ន្ធនឹងការកំណត់ការវាយតម្លៃ ២/- ប្រភពជាក់លាក់នៃព័ត៌មានទីផ្សារ និងការពិនិត្យលើភាពជឿទុកចិត្តបាននៃព័ត៌មាននោះ និង ៣/- ភាពញឹកញាប់នៃការផ្ទៀងផ្ទាត់ដោយឯករាជ្យ ដូចមានកំណត់ក្នុងប្រការ ១០ នៃប្រកាសនេះ និង

- យន្តការរាយការណ៍ច្បាស់លាស់ និងឯករាជ្យ សម្រាប់ផ្នែកគ្រប់គ្រងហានិភ័យដែលទទួលខុសត្រូវចំពោះដំណើរការវាយតម្លៃ និងមានឯករាជ្យភាពពីការិយាល័យជួរមុខ (មុខងារវិនិយោគ)។

**ប្រការ ១០.- ការផ្ទៀងផ្ទាត់ថ្លៃដោយឯករាជ្យ**

ក្រៅពីការធ្វើម៉ាកធូម៉ាខេតប្រចាំថ្ងៃ គ្រឹះស្ថានត្រូវផ្ទៀងផ្ទាត់ថ្លៃដោយឯករាជ្យ។ ការផ្ទៀងផ្ទាត់នេះជាដំណើរការដែលត្រូវអនុវត្តជាប្រចាំដើម្បីធានាពីភាពត្រឹមត្រូវនៃថ្លៃទីផ្សារ។ ការផ្ទៀងផ្ទាត់ថ្លៃទីផ្សារត្រូវធ្វើឡើងដោយផ្នែកគ្រប់គ្រងហានិភ័យដែលមានឯករាជ្យភាពពីការិយាល័យជួរមុខ ក្នុងគោលបំណងបង្ហាញពីកំហុសឆ្គង ឬភាពលម្អៀងនៅក្នុងការកំណត់ថ្លៃរបស់ការិយាល័យជួរមុខ។ ការផ្ទៀងផ្ទាត់នេះត្រូវធ្វើឡើងជាប្រចាំយ៉ាងហោចណាស់រៀងរាល់ខែ ឬញឹកញាប់ជាងនេះតាមការចាំបាច់ផ្អែកតាមប្រភេទនិងហានិភ័យនៃសកម្មភាពជួញដូរ។

**ប្រការ ១១.- បញ្ជិកាជួញដូរ និងបញ្ជិកាធនាគារ**

ចំពោះការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារ គ្រឹះស្ថានត្រូវគិតបញ្ចូលតែប៉ូស៊ីសិននៅក្នុងបញ្ជិកាជួញដូរប៉ុណ្ណោះ ប៉ុន្តែចំពោះហានិភ័យអត្រាប្តូរប្រាក់ គ្រឹះស្ថានត្រូវគិតបញ្ចូលទាំងប៉ូស៊ីសិននៅក្នុងបញ្ជិកាជួញដូរ និងបញ្ជិកាធនាគារ។ ប៉ូស៊ីសិនទាំងនេះ រួមបញ្ចូលឧបករណ៍ដែលបំពេញបានតាមលក្ខខណ្ឌអប្បបរមា ដូចខាងក្រោម៖

ក. មិនមានឧបសគ្គផ្នែកច្បាប់ដែលរារាំងការលក់ ឬការការពារពេញលេញចំពោះឧបករណ៍ទាំងនោះ និង

ខ. មានការវាយតម្លៃទីផ្សារប្រចាំថ្ងៃ ហើយបម្រែបម្រួលថ្លៃត្រូវបានកត់ត្រាក្នុងគណនីចំណេញ/ខាត។

គ្រឹះស្ថានត្រូវកត់ត្រាឧបករណ៍ហិរញ្ញវត្ថុទៅក្នុងបញ្ជិកាជួញដូរ ចាប់តាំងពីថ្ងៃធ្វើប្រតិបត្តិការដំបូង។ ឧបករណ៍ហិរញ្ញវត្ថុទាំងឡាយដែលមិនត្រូវបានកត់ត្រាក្នុងបញ្ជិកាជួញដូរ ត្រូវកត់ត្រាក្នុងបញ្ជិកាធនាគារ។

## ជំពូកទី ៣

## ការគណនាទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យទីផ្សារ

### ផ្នែក ១៖ បន្ទុកដើមទុនសម្រាប់ហានិភ័យទីផ្សារ

**ប្រការ ១២.- រូបមន្ត**

បន្ទុកដើមទុនសម្រាប់ហានិភ័យទីផ្សារ ត្រូវបានគណនាដូចខាងក្រោម៖

**បន្ទុកដើមទុនសម្រាប់ហានិភ័យទីផ្សារ** $= (CR_{IRR} \times SF_{IRR}) + (CR_{EQ} \times SF_{EQ}) + (CR_{FX} \times SF_{FX})$

ដែល៖

- $CR_{IRR}$ = កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាការប្រាក់ បូកនិងកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអប់ហ្សិនពីឧបករណ៍បំណុល
- $CR_{EQ}$ = កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យមូលបត្រកម្មសិទ្ធិ បូកនិងកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអប់ហ្សិនពីឧបករណ៍មូលបត្រកម្មសិទ្ធិ

- $CR_{FX}$ = កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាប្តូរប្រាក់ បូកនិងកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអប់ហ្សិនពីឧបករណ៍ហិរញ្ញវត្ថុពាក់ព័ន្ធនឹងអត្រាប្តូរប្រាក់
- $SF_{IRR}$ = មេគុណថ្លឹងសម្រាប់ហានិភ័យអត្រាការប្រាក់ត្រូវបានកំណត់ ១,៣០
- $SF_{EQ}$ = មេគុណថ្លឹងសម្រាប់ហានិភ័យមូលបត្រកម្មសិទ្ធិត្រូវបានកំណត់ ៣,៥០ និង
- $SF_{FX}$ = មេគុណថ្លឹងសម្រាប់ហានិភ័យអត្រាប្តូរប្រាក់ត្រូវបានកំណត់ ១,២០។

យោងតាមការគណនាបន្ទុកដើមទុនខាងលើ គ្រឹះស្ថានអាចគណនាទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យទីផ្សារ តាមរូបមន្តដូចខាងក្រោម៖

| | |
|---|---|
| **ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យទីផ្សារ** | **= បន្ទុកដើមទុនសម្រាប់ហានិភ័យទីផ្សារ X ១២,៥០** |

**ប្រការ ១៣.- ការគណនាកាតព្វកិច្ចដើមទុន**

ហានិភ័យទីផ្សារត្រូវបានវាយតម្លៃលើប៉ូស៊ីសិននៅក្នុងបញ្ជិកាជួញដូរ ដែលមានសមាសធាតុ ២ ដូចខាងក្រោម៖

**ក. ហានិភ័យជាក់លាក់** សំដៅដល់ហានិភ័យនៃការខាតបង់តម្លៃនៃប៉ូស៊ីសិននៅក្នុងបញ្ជិកាជួញដូរ ដែលកើតឡើងពីបម្រែបម្រួលថ្លៃនៃមូលបត្របំណុល មូលបត្រកម្មសិទ្ធិ និងកិច្ចសន្យានៃឧបករណ៍និស្សន្ទទាំងឡាយណាដែលពាក់ព័ន្ធនឹងអ្នកបោះផ្សាយនៃឧបករណ៍ទាំងនោះ នៅក្នុងបញ្ជិកាជួញដូរ និង

**ខ. ហានិភ័យទីផ្សារទូទៅ** សំដៅដល់ហានិភ័យនៃការខាតបង់ពាក់ព័ន្ធនឹងឧបករណ៍ហិរញ្ញវត្ថុក្នុងបញ្ជិកាជួញដូរ ដោយសារបម្រែបម្រួលអត្រាការប្រាក់ទីផ្សារ ថ្លៃមូលបត្រកម្មសិទ្ធិ និងអត្រាប្តូរប្រាក់។

ហានិភ័យជាក់លាក់ និងហានិភ័យទីផ្សារទូទៅ ដែលកើតមានចំពោះហានិភ័យទីផ្សារ មានបង្ហាញ ដូចខាងក្រោម៖

| សមាសធាតុហានិភ័យទីផ្សារ | ហានិភ័យជាក់លាក់ | ហានិភ័យទីផ្សារទូទៅ |
|---|---|---|
| អត្រាការប្រាក់ | មាន | មាន |
| មូលបត្រកម្មសិទ្ធិ | មាន | មាន |
| អត្រាប្តូរប្រាក់ | គ្មាន | មាន |
| ឧបករណ៍និស្សន្ទ | យោងទៅឧបសម្ព័ន្ធ ៤ និង៥ | |
| អប់ហ្សិន | ប៉ូស៊ីសិនជាអប់ហ្សិន និងប៉ូស៊ីសិននៃឧបករណ៍សាមីត្រូវបានគណនាដាច់ដោយឡែកពីប៉ូស៊ីសិនដទៃទៀតនៅក្នុងបញ្ជិកាជួញដូរ។ | |

## ផ្នែក ២៖ ភាគព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាការប្រាក់

### ប្រការ ១៤.- ឧបករណ៍ដែលរាប់បញ្ចូលក្នុងការគណនាភាគព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាការប្រាក់

ឧបករណ៍ហិរញ្ញវត្ថុដែលរាប់បញ្ចូលក្នុងការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាការប្រាក់ រួមមាន មូលបត្របំណុល និងឧបករណ៍ដទៃទៀតដែលពាក់ព័ន្ធនឹងអត្រាការប្រាក់នៅក្នុងបញ្ជិកាជួញដូរ ដូចជា កិច្ចសន្យារីប៉ូ និងកិច្ចសន្យារីវើសរីប៉ូ។ ឧបករណ៍ទាំងនោះរាប់បញ្ចូលមូលបត្របំណុលដែលមានអត្រាការប្រាក់ថេរនិងអត្រាការប្រាក់អណ្តែត និងឧបករណ៍ដទៃទៀតដែលមានលក្ខណៈប្រហាក់ប្រហែល រួមទាំង ភាគហ៊ុនអាទិភាពដែលមិនអាចប្តូរបានជាភាគហ៊ុនទូទៅ។ សញ្ញាបណ្ណដែលអាចប្តូរបាន ត្រូវបានចាត់ទុកជាមូលបត្របំណុល ប្រសិនបើសញ្ញាបណ្ណនោះត្រូវបានជួញដូរដូចមូលបត្របំណុល។

ប្រព័ន្ធវាស់វែងហានិភ័យអត្រាការប្រាក់ត្រូវរាប់បញ្ចូលឧបករណ៍និស្សន្ទទាំងអស់នៅក្នុងបញ្ជិកាជួញដូរ ដែលប្រែប្រួលតាមអត្រាការប្រាក់ ដូចជា កិច្ចសន្យាស្វបអត្រាការប្រាក់ (Interest rate swaps) កិច្ចសន្យាហ្វូឈើរសញ្ញាបណ្ណ (Bond futures) កិច្ចសន្យាស្វបឆ្លងរូបិយបណ្ណ (Cross-currency swaps) ប៉ូស៊ីសិនហ្វ័រវើដប្តូររូបិយបណ្ណ (Forward foreign exchange position) កិច្ចព្រមព្រៀងហ្វ័រវើដអត្រាការប្រាក់ (Forward rate agreement) និងកិច្ចសន្យាហ្វ័រវើដផ្សេងៗ (Other forward contracts)។ វិធីសាស្រ្តគណនាហានិភ័យអត្រាការប្រាក់សម្រាប់អប់ហ្សិន មានកំណត់ក្នុងប្រការ ២៩ នៃប្រកាសនេះ។

ចំពោះឧបករណ៍ហិរញ្ញវត្ថុដូចគ្នា (សំដៅដល់អ្នកបោះផ្សាយ អត្រាគូប៉ុង រូបិយបណ្ណ និងឥណប្រតិទាន ដូចគ្នា) គ្រឹះស្ថានត្រូវដកចេញនូវចំនួនដែលអាចកាត់កងរវាងឡុងប៉ូស៊ីសិន និងសតប៉ូស៊ីសិន ពីការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាការប្រាក់ ទាំងហានិភ័យជាក់លាក់ និងហានិភ័យទីផ្សារទូទៅ។ គ្រឹះស្ថានមិនត្រូវកាត់កងប៉ូស៊ីសិននៃឧបករណ៍ហិរញ្ញវត្ថុដែលមានចរិតលក្ខណៈខុសគ្នា ទោះបីជាអ្នកបោះផ្សាយតែមួយក៏ដោយ។ កិច្ចសន្យាហ្វូឈើរ ឬ កិច្ចសន្យាហ្វ័រវើដ ដែលបានកាត់កងទាំងស្រុងដោយទ្រព្យសកម្មសាមី ត្រូវបានដកចេញពីការគណនាកាតព្វកិច្ចដើមទុន។

គ្រឹះស្ថានត្រូវរៀបចំរបាយការណ៍ដាច់ដោយឡែកអំពីការកាត់កងប៉ូស៊ីសិននៃឧបករណ៍ហិរញ្ញវត្ថុដូចគ្នា និងការកាត់កងរវាងឧបករណ៍និស្សន្ទនិងទ្រព្យសកម្មសាមី ដែលត្រូវដកចេញពីការគណនាហានិភ័យអត្រាការប្រាក់ទាំងហានិភ័យជាក់លាក់ និងហានិភ័យទីផ្សារទូទៅ។

### ប្រការ ១៥.- សមាសធាតុហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ កើតឡើងពីសមាសធាតុ ២ គឺ ១/- "ហានិភ័យជាក់លាក់" និង ២/- "ហានិភ័យទីផ្សារទូទៅ"។ គ្រឹះស្ថានត្រូវគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាការប្រាក់ ដោយកំណត់ប៉ូស៊ីសិននៅក្នុងបញ្ជិកាជួញដូរដែលមានហានិភ័យអត្រាការប្រាក់ និងត្រូវបែងចែកប៉ូស៊ីសិនទៅតាមសំពៀតរូបិយបណ្ណសំខាន់នីមួយៗ (សម្រាប់តែហានិភ័យទីផ្សារទូទៅប៉ុណ្ណោះ)។ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាការប្រាក់ ជាផលបូកនៃកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យជាក់លាក់ និង កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារទូទៅទៅតាមសំពៀតរូបិយបណ្ណសំខាន់នីមួយៗដោយមិនចាំបាច់គិតពីសញ្ញាផ្ទុយគ្នា (កាតព្វកិច្ចដើមទុនត្រូវបានកត់ត្រាជាតម្លៃដាច់ខាត)។ រូបិយបណ្ណសំខាន់ នឹងមានកំណត់ក្នុង "សេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ"។

នៅពេលគ្រឹះស្ថានមានប៉ូស៊ីសិនជារូបិយបណ្ណមួយ ឬច្រើនក្រៅពីរូបិយបណ្ណសំខាន់ដែលមានកំណត់ក្នុងសេចក្តីណែនាំ រូបិយបណ្ណទាំងនោះត្រូវចាត់ទុកជា "រូបិយបណ្ណផ្សេងទៀត" ហើយគ្រឹះស្ថានត្រូវរៀបចំតារាងឥណប្រតិទានច្រើនកម្រិត សម្រាប់រូបិយបណ្ណទាំងនោះ និងកត់ត្រាឡុងប៉ូស៊ីសិនសុទ្ធ និងសតប៉ូស៊ីសិនសុទ្ធសម្រាប់រូបិយបណ្ណនីមួយៗទៅតាមថាមប៉ៃន (Time band) ដោយមិនចាំបាច់បង្កើតតារាងឥណប្រតិទានច្រើនកម្រិតដាច់ដោយឡែកពីគ្នាទេ។ ដើម្បីគណនាប៉ូស៊ីសិនដុលសម្រាប់ហានិភ័យអត្រាការប្រាក់ គ្រឹះស្ថានត្រូវបូកតម្លៃដាច់ខាតនៃប៉ូស៊ីសិនសុទ្ធនៃជារូបិយបណ្ណនីមួយៗ ដោយមិនគិតពីឡុងប៉ូស៊ីសិន ឬសតប៉ូស៊ីសិន។ ប៉ូស៊ីសិនដុលនៃថាមប៉ៃននីមួយៗ ត្រូវបូកបញ្ចូលគ្នាដើម្បីទទួលបានប៉ូស៊ីសិនដុលសរុបសម្រាប់ "រូបិយបណ្ណផ្សេងទៀត"។

**ប្រការ ១៦.- ហានិភ័យជាក់លាក់**

កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យជាក់លាក់ គឺជាផលបូកសរុបនៃតម្លៃដាច់ខាតនៃឡុងប៉ូស៊ីសិនសុទ្ធទាំងអស់ និងសតប៉ូស៊ីសិនសុទ្ធទាំងអស់ដែលបានថ្លឹង នៃឧបករណ៍ហិរញ្ញវត្ថុពាក់ព័ន្ធ។ ប៉ូស៊ីសិននីមួយៗត្រូវបានថ្លឹងទៅតាមកម្រិតថ្លឹងហានិភ័យជាក់លាក់ ដែលឆ្លុះបញ្ចាំងពីគុណភាព និងឥណប្រតិទាននៃឧបករណ៍នោះ។ សម្រាប់គោលបំណងនៃប្រកាសនេះ ប៉ូស៊ីសិននៃឧបករណ៍ហិរញ្ញវត្ថុពាក់ព័ន្ធនឹងអត្រាការប្រាក់ត្រូវបានបែងចែកជា ៣ ប្រភេទ គឺ "មូលបត្របំណុលរដ្ឋ" "មូលបត្របំណុលមានលក្ខណៈគ្រប់គ្រាន់" និង "មូលបត្របំណុលផ្សេងៗ"។

ក. "មូលបត្របំណុលរដ្ឋ" រួមមាន៖

- មូលបត្របំណុលគ្រប់ប្រភេទដែលបោះផ្សាយឬធានាទាំងស្រុងដោយរាជរដ្ឋាភិបាលកម្ពុជា
- មូលបត្របំណុលដែលបោះផ្សាយ ដោយធនាគារជាតិនៃកម្ពុជា ឬ
- មូលបត្របំណុលដែលបោះផ្សាយឬធានាទាំងស្រុងដោយរដ្ឋាភិបាល ឬធនាគារកណ្តាលនៃប្រទេសផ្សេង ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មចំណាត់ថ្នាក់ដោយភ្នាក់ងារចាត់ថ្នាក់ឥណទាន (ECAI) ផ្អែកលើលទ្ធភាពទូទាត់សងបំណុលរបស់ប្រទេសដែលបោះផ្សាយមូលបត្រនោះ។

ខ. "មូលបត្របំណុលមានលក្ខណៈគ្រប់គ្រាន់" រួមមាន៖

- មូលបត្របំណុលដែលបោះផ្សាយឬធានាទាំងស្រុងដោយធនាគារអភិវឌ្ឍន៍ពហុភាគី ដូចជា ក្រុមរបស់ធនាគារពិភពលោក (ធនាគារអន្តរជាតិសម្រាប់ការស្តារនិងអភិវឌ្ឍ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ភ្នាក់ងារធានារ៉ាប់រងវិនិយោគពហុភាគី និងសមាគមអភិវឌ្ឍន៍អន្តរជាតិ) ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអភិវឌ្ឍន៍ថ្មី ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី និងធនាគារអឺរ៉ុបសម្រាប់ការស្តារនិងអភិវឌ្ឍ។ មូលបត្របំណុលទាំងនេះត្រូវមានចំណាត់ថ្នាក់វិនិយោគដោយ ECAI យ៉ាងតិចចំនួនមួយ
- មូលបត្របំណុលផ្សេងទៀត ដែលមានចំណាត់ថ្នាក់វិនិយោគដោយ ECAI យ៉ាងតិចចំនួនមួយ និងអ្នកបោះផ្សាយមូលបត្រនេះបានបោះផ្សាយមូលបត្រនៅលើទីផ្សារផ្លូវការ ឬ
- មូលបត្របំណុលផ្សេងទៀត ដែលមានចំណាត់ថ្នាក់វិនិយោគដោយ ECAI យ៉ាងតិច ចំនួនពីរ។

គ. "មូលបត្របំណុលផ្សេងៗ" គឺជាមូលបត្របំណុលដែលមិនមែនជា "មូលបត្របំណុលរដ្ឋ" និង "មូលបត្របំណុលមានលក្ខណៈគ្រប់គ្រាន់"។

កម្រិតថ្លឹងហានិភ័យជាក់លាក់ចំពោះឧបករណ៍ពាក់ព័ន្ធនឹងអត្រាការប្រាក់ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ៣។

**ប្រការ ១៧.- ហានិភ័យទីផ្សារទូទៅ**

កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារទូទៅ ត្រូវបានគណនាដោយបូកបញ្ចូលសមាសធាតុទាំងបួន ដូចខាងក្រោម៖

- ១០០% នៃផលបូកសរុបនៃប៉ូស៊ីសិនសុទ្ធនៃរូបិយវត្ថុ/រូបិយបណ្ណសំខាន់ និងប៉ូស៊ីសិនដុលនៃ "រូបិយបណ្ណផ្សេងទៀត" ដោយមិនគិតពីសញ្ញា +/- នៅក្នុងបញ្ជិកាជួញដូរ សម្រាប់កំណត់កាតព្វកិច្ចដើមទុន ដើម្បីរ៉ាប់រងហានិភ័យដាយរិចសិនណល (Directional risk)
- ១០% នៃចំនួនប៉ូស៊ីសិនផ្ទុយផ្គងនៅក្នុងថាមប៊ែននីមួយៗ សម្រាប់កំណត់កាតព្វកិច្ចដើមទុនដោយមិនអនុញ្ញាតឱ្យកាត់កងជួរឈរ (Vertical disallowance) ដើម្បីរ៉ាប់រងហានិភ័យបេស៊ីស
- ៤០%, ៣០% ឬ ១០០% នៃប៉ូស៊ីសិនផ្ទុយផ្គងនៅក្នុងថាមហ្សូន (Time zone) តែមួយ ឬឆ្លងថាមហ្សូន សម្រាប់កំណត់កាតព្វកិច្ចដើមទុន ដោយមិនអនុញ្ញាតឱ្យកាត់កងជួរដេក (Horizontal disallowance) ដើម្បីរ៉ាប់រងហានិភ័យខ្សែកោងទិន្នផល និង
- កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអប់ហ្សិន ដែលពាក់ព័ន្ធនឹងអត្រាការប្រាក់ ដូចមានកំណត់ក្នុងប្រការ ២៩ នៃប្រកាសនេះ។

ការគណនាផលបូកនៃសមាសធាតុទាំងបួនខាងលើ មានពន្យល់លម្អិតក្នុង "សេចក្តីណែនាំស្តីពីការអនុវត្តប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ"។

**ប្រការ ១៨.- ឧបករណ៍និស្សន្ទពាក់ព័ន្ធនឹងអត្រាការប្រាក់**

ក្នុងការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាការប្រាក់ គ្រឹះស្ថានត្រូវរាប់បញ្ចូលឧបករណ៍និស្សន្ទពាក់ព័ន្ធនឹងអត្រាការប្រាក់ និងឧបករណ៍ក្រៅតារាងតុល្យការនៅក្នុងបញ្ជិកាជួញដូរដែលប្រែប្រួលតាមអត្រាការប្រាក់។ នៅពេលគណនាកាតព្វកិច្ចដើមទុននៃឧបករណ៍និស្សន្ទ ដំបូងគ្រឹះស្ថានត្រូវប្តូរឧបករណ៍និស្សន្ទទៅជាតម្លៃទ្រព្យសកម្មសាមី។ បន្ទាប់មក គ្រឹះស្ថានត្រូវគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យជាក់លាក់ និងហានិភ័យទីផ្សារទូទៅ ដោយផ្អែកលើប្រភេទនៃទ្រព្យសកម្មទាំងនោះ ប្រសិនបើមាន។ វិធានក្នុងការគណនាមានកំណត់ក្នុង "សេចក្តីណែនាំស្តីពីការអនុវត្តប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ"។ ដូច្នេះ ចំនួនដែលត្រូវដាក់បញ្ចូលក្នុងការគណនាកាតព្វកិច្ចដើមទុន ត្រូវគិតតាមតម្លៃទីផ្សារនៃចំនួនប្រាក់ដើមរបស់មូលបត្រសាមី ឬណូសិនណលមូលបត្រសាមី ដែលទទួលបានពីការវាយតម្លៃតាមវិធីសាស្ត្រដូចមានកំណត់ក្នុងប្រការ ៩ នៃប្រកាសនេះ។

តារាងសង្ខេបស្តីពីកាតព្វកិច្ចដើមទុនសម្រាប់ឧបករណ៍និស្សន្ទពាក់ព័ន្ធនឹងអត្រាការប្រាក់មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤។

**ប្រការ ១៩.- ហានិភ័យជាក់លាក់សម្រាប់ឧបករណ៍និស្សន្ទពាក់ព័ន្ធនឹងអត្រាការប្រាក់**

កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យជាក់លាក់ មិនត្រូវបានគណនាចំពោះឧបករណ៍និស្សន្ទមួយចំនួន ដូចជា កិច្ចសន្យាស្វបអត្រាការប្រាក់ កិច្ចសន្យាស្វបឆ្លងរូបិយបណ្ណ កិច្ចសន្យាហ្វ័រវើដអត្រាការប្រាក់ កិច្ចសន្យាហ្វ័រវើដប្តូររូបិយបណ្ណ កិច្ចសន្យាហ្វូឈ័រអត្រាការប្រាក់ និងកិច្ចសន្យាហ្វូឈ័រសន្ទស្សន៍អត្រាការប្រាក់។ ក្នុងករណីឧបករណ៍និស្សន្ទមានទ្រព្យសកម្មសាមីជាប្រភេទមូលបត្របំណុល ឬសន្ទស្សន៍មូលបត្របំណុល ការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យជាក់លាក់ត្រូវអនុវត្តស្របតាមហានិភ័យជាក់លាក់នៃអ្នកបោះផ្សាយមូលបត្របំណុលនោះ ដូចមានកំណត់ក្នុងប្រការ ១៦ នៃប្រកាសនេះ។

**ប្រការ ២០.- ហានិភ័យទីផ្សារទូទៅសម្រាប់ឧបករណ៍និស្សន្ទពាក់ព័ន្ធនឹងអត្រាការប្រាក់**

ការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារទូទៅចំពោះប៉ូស៊ីសិននៃគ្រប់ឧបករណ៍និស្សន្ទទាំងអស់ (លើកលែងតែប៉ូស៊ីសិនដែលត្រូវបានកាត់កងទាំងស្រុងចំពោះឧបករណ៍ហិរញ្ញវត្ថុដូចគ្នា ដូចមានកំណត់ក្នុងប្រការ ៨ និងប្រការ ១៨ នៃប្រកាសនេះ) ត្រូវដូចគ្នានឹងការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារទូទៅ ចំពោះឧបករណ៍ក្នុងតារាងតុល្យការ (ប៉ូស៊ីសិនជាសាច់ប្រាក់)។ វិធាននិងជំហាននៃការគណនាកាតព្វកិច្ចដើមទុនសម្រាប់ឧបករណ៍និស្សន្ទពាក់ព័ន្ធនឹងអត្រាការប្រាក់ មានពន្យល់លម្អិតក្នុង "សេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ"។

## ផ្នែក ៣៖ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យមូលបត្រកម្មសិទ្ធិ

**ប្រការ ២១.- ឧបករណ៍ដែលរាប់បញ្ចូលក្នុងការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យមូលបត្រកម្មសិទ្ធិ**

ហានិភ័យមូលបត្រកម្មសិទ្ធិកើតមានឡើងនៅពេលគ្រឹះស្ថានកាន់កាប់ប៉ូស៊ីសិននៃឧបករណ៍ហិរញ្ញវត្ថុទាំងឡាយណាដែលមានចរិតលក្ខណៈដូចមូលបត្រកម្មសិទ្ធិ នៅក្នុងបញ្ជិកាជួញដូរ។ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យនេះ ត្រូវបានអនុវត្តចំពោះប៉ូស៊ីសិនក្នុងបញ្ជិកាជួញដូរសម្រាប់ឧបករណ៍ហិរញ្ញវត្ថុមួយចំនួន ដូចខាងក្រោម៖

- ភាគហ៊ុនទូទៅ (ទោះបីមាន ឬ គ្មានសិទ្ធិបោះឆ្នោត)
- ភាគហ៊ុនអាទិភាព ដែលអាចប្តូរជាភាគហ៊ុនទូទៅ
- មូលបត្របំណុលដែលអាចប្តូរបាន នៅពេលមូលបត្រទាំងនោះត្រូវបានជួញដូរដូចមូលបត្រកម្មសិទ្ធិ
- ឧបករណ៍និស្សន្ទមូលបត្រកម្មសិទ្ធិ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដែលមានចរិតលក្ខណៈដូចមូលបត្រកម្មសិទ្ធិ។

ប៉ូស៊ីសិនផ្ទុយគ្នានៅក្នុងមូលបត្រកម្មសិទ្ធិ ឬសន្ទស្សន៍ភាគហ៊ុនតែមួយនៅក្នុងទីផ្សារដូចគ្នាអាចកាត់កងបានដើម្បីទទួលបានឡុងប៉ូស៊ីសិនសុទ្ធ ឬសតប៉ូស៊ីសិនសុទ្ធ ក្នុងការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យជាក់លាក់ និងហានិភ័យទីផ្សារទូទៅ។ ឧទាហរណ៍៖ កិច្ចសន្យាហ្វូឈ័រមូលបត្រកម្មសិទ្ធិ អាចកាត់កងជាមួយប៉ូស៊ីសិនជាសាច់ប្រាក់ដែលផ្ទុយគ្នាចំពោះមូលបត្រកម្មសិទ្ធិដូចគ្នា។

**ប្រការ ២២.- សមាសធាតុហានិភ័យមូលបត្រកម្មសិទ្ធិ**

កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យមូលបត្រកម្មសិទ្ធិ ជាផលបូកនៃសមាសធាតុ ២ គឺ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យជាក់លាក់នៃការកាន់កាប់ប៉ូស៊ីសិនក្នុងមូលបត្រកម្មសិទ្ធិនីមួយៗ និងកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារទូទៅ នៃការកាន់កាប់ប៉ូស៊ីសិនមូលបត្រកម្មសិទ្ធិ នៅក្នុងទីផ្សារទាំងមូល។

កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យជាក់លាក់ ត្រូវបានកំណត់ ៨% នៃប៉ូស៊ីសិនមូលបត្រកម្មសិទ្ធិដុល (បន្ទាប់ពីការកាត់កងឡុងប៉ូស៊ីសិននិងសតប៉ូស៊ីសិននៃមូលបត្រកម្មសិទ្ធិពីអ្នកបោះផ្សាយតែមួយ និងមានចរិតលក្ខណៈដូចគ្នាទាំងស្រុង)។ ប៉ូស៊ីសិនមូលបត្រកម្មសិទ្ធិដុលរបស់គ្រឹះស្ថាន គឺជាផលបូកតម្លៃដាច់ខាតនៃឡុងប៉ូស៊ីសិន និងសតប៉ូស៊ីសិនមូលបត្រកម្មសិទ្ធិទាំងអស់។

កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារទូទៅ ត្រូវបានកំណត់ ៨% នៃភាពខុសគ្នារវាងឡុងប៉ូស៊ីសិនមូលបត្រកម្មសិទ្ធិសរុប និងសតប៉ូស៊ីសិនមូលបត្រកម្មសិទ្ធិសរុប មានន័យថា ៨% នៃប៉ូស៊ីសិនសុទ្ធនៅក្នុងទីផ្សារមូលបត្រកម្មសិទ្ធិ។

គ្រឹះស្ថានត្រូវគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យមូលបត្រកម្មសិទ្ធិដាច់ដោយឡែកពីគ្នាទៅតាមទីផ្សារដែលគ្រឹះស្ថានជួញដូរ។ កាតព្វកិច្ចដើមទុនសរុប គឺជាផលបូកកាតព្វកិច្ចដើមទុនសម្រាប់ទីផ្សារទាំងអស់។

ឧទាហរណ៍ពីការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យមូលបត្រកម្មសិទ្ធិ មានបង្ហាញក្នុង "សេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ"។

**ប្រការ ២៣.- ឧបករណ៍និស្សន្ទមូលបត្រកម្មសិទ្ធិ**

រាល់ឧបករណ៍និស្សន្ទមូលបត្រកម្មសិទ្ធិ និងប៉ូស៊ីសិនក្រៅតារាងតុល្យការផ្សេងទៀតក្នុងបញ្ជិកាជួញដូរដែលរងផលប៉ះពាល់ពីបម្រែបម្រួលថ្លៃមូលបត្រកម្មសិទ្ធិ ត្រូវរាប់បញ្ចូលក្នុងការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យមូលបត្រកម្មសិទ្ធិទាំងហានិភ័យជាក់លាក់ និងហានិភ័យទីផ្សារទូទៅ។ ការគណនាត្រូវធ្វើឡើងទាំងឧបករណ៍និស្សន្ទសម្រាប់មូលបត្រកម្មសិទ្ធិនីមួយៗ និងសម្រាប់សន្ទស្សន៍មូលបត្រកម្មសិទ្ធិ។

ការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអប់ហ្សិនមូលបត្រកម្មសិទ្ធិ មានកំណត់ក្នុងប្រការ ២៩ នៃប្រកាសនេះ។

**ប្រការ ២៤.- កាតព្វកិច្ចដើមទុនសម្រាប់ឧបករណ៍និស្សន្ទមូលបត្រកម្មសិទ្ធិ**

ក្នុងការគណនាកាតព្វកិច្ចដើមទុនសម្រាប់ឧបករណ៍និស្សន្ទមូលបត្រកម្មសិទ្ធិ ដំបូងគ្រឹះស្ថានត្រូវបំប្លែងឧបករណ៍និស្សន្ទទៅជាប៉ូស៊ីសិនមូលបត្រកម្មសិទ្ធិសាមី (Underlying equities) ដូចខាងក្រោម៖

- កិច្ចសន្យាហ្វូឈឺរនិងហ្វ័រវើដពាក់ព័ន្ធនឹងមូលបត្រកម្មសិទ្ធិនីមួយៗ ត្រូវគិតតាមតម្លៃទីផ្សារនៃមូលបត្រកម្មសិទ្ធិ

- កិច្ចសន្យាហិរញ្ញវត្ថុពាក់ព័ន្ធនឹងសន្ទស្សន៍ភាគហ៊ុន ត្រូវគិតតាមតម្លៃម៉ាកធូម៉ាខេតនៃល្វាសិនណលសំរៀតមូលបត្រកម្មសិទ្ធិសាមី ឬ
- ស្វបមូលបត្រកម្មសិទ្ធិ ត្រូវកំណត់ជាពីរល្វាសិនណលប៉ូស៊ីសិន។

តារាងសង្ខេបស្តីពីកាតព្វកិច្ចដើមទុនសម្រាប់ឧបករណ៍និស្សន្ទមូលបត្រកម្មសិទ្ធិ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥។

## ផ្នែក ៤៖ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាប្តូរប្រាក់

### ប្រការ ២៥.- កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាប្តូរប្រាក់

កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាប្តូរប្រាក់ត្រូវបានកំណត់ ៨% នៃ "ប៉ូស៊ីសិនចំហសុទ្ធសរុប"។

### ប្រការ ២៦.- ការគណនាប៉ូស៊ីសិនជារូបិយបណ្ណ និងមាស

កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាប្តូរប្រាក់ អនុវត្តចំពោះការកាន់កាប់ប៉ូស៊ីសិនជារូបិយបណ្ណ និងមាស ទាំងប៉ូស៊ីសិននៅក្នុងបញ្ជិកាធនាគារ និងបញ្ជិកាជួញដូរ។

គ្រឹះស្ថានត្រូវគណនាប៉ូស៊ីសិននៃរូបិយបណ្ណ និងមាស ជា ២ ដំណាក់កាល ដូចខាងក្រោម៖

- ដំណាក់កាលទី១ ៖ គណនាប៉ូស៊ីសិនចំហសុទ្ធនៃរូបិយបណ្ណនីមួយៗ និងមាស និង
- ដំណាក់កាលទី២ ៖ គណនា "ប៉ូស៊ីសិនចំហសុទ្ធសរុប" នៃរូបិយបណ្ណ និងបូកបន្ថែមទាំងតម្លៃដាច់ខាតប៉ូស៊ីសិនចំហសុទ្ធជាមាស។

### ប្រការ ២៧.- ការគណនាប៉ូស៊ីសិនចំហសុទ្ធសរុបនៃរូបិយបណ្ណនីមួយៗ និងមាស

ប៉ូស៊ីសិនចំហសុទ្ធសរុបនៃរូបិយបណ្ណនីមួយៗនិងមាសរបស់គ្រឹះស្ថាន ជាផលបូកនៃ៖

- ប៉ូស៊ីសិនដល់ដៃសុទ្ធ (ទ្រព្យសកម្មសរុប ដក ទ្រព្យអកម្ម និងមូលនិធិភាគទុនិកសរុប រួមទាំងការប្រាក់បង្គរ ទៅតាមរូបិយបណ្ណនីមួយៗ)
- ប៉ូស៊ីសិនហ្វ័រវើដសុទ្ធ (ចំនួនសរុបដែលត្រូវទទួល ដក ចំនួនសរុបដែលត្រូវចំណាយក្រោមប្រតិបត្តិការហ្វ័រវើដប្តូររូបិយបណ្ណ រួមទាំងហ្វូឈ័ររូបិយបណ្ណ និងប្រាក់ដើមនៃស្វបរូបិយបណ្ណដែលមិនរាប់បញ្ចូលនៅក្នុងប៉ូស៊ីសិនដល់ដៃ)
- ការធានា និងឧបករណ៍ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ដែលនឹងត្រូវអនុវត្ត និងជាទូទៅមិនអាចប្រមូលមកវិញបាន និង
- ខ្ទង់ដទៃទៀតដែលតំណាងឱ្យចំណេញ ឬខាតពីការប្តូររូបិយបណ្ណ។

កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាប្តូរប្រាក់ចំពោះអប់ហ្សិនប្តូររូបិយបណ្ណ ត្រូវគណនាដាច់ដោយឡែកដូចមានកំណត់ក្នុងប្រការ ២៩ នៃប្រកាសនេះ។

នៅពេលគណនាហានិភ័យអត្រាប្តូរប្រាក់ គ្រឹះស្ថានមិនត្រូវកាត់កងរវាងប៉ូស៊ីសិនជារូបិយបណ្ណខុសគ្នាទេ។ ការគណនាប៉ូស៊ីសិនចំហសុទ្ធសម្រាប់ហានិភ័យអត្រាប្តូរប្រាក់មានកំណត់ក្នុង "សេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ"។ h

## ប្រការ ២៨.- ការគណនា "ប៉ូស៊ីសិនចំហសុទ្ធសរុប"

"ប៉ូស៊ីសិនចំហសុទ្ធសរុប" ត្រូវគណនាដោយបូកតម្លៃដាច់ខាតនៃ៖

- ចំនួនដែលធំជាងគេរវាងឡុងប៉ូស៊ីសិនសុទ្ធសរុប និងសតប៉ូស៊ីសិនសុទ្ធសរុបនៃរូបិយបណ្ណ និង
- ប៉ូស៊ីសិនសុទ្ធជាមាស (សតប៉ូស៊ីសិន ឬឡុងប៉ូស៊ីសិន)។

ឧទាហរណ៍នៃការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាប្តូរប្រាក់មានកំណត់ក្នុង "សេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ"។

# ផ្នែក ៥៖ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអប់ហ្សិន

## ប្រការ ២៩.- ការទិញខលអប់ហ្សិន ឬ ភុតអប់ហ្សិន

គ្រឹះស្ថានអាចទិញអប់ហ្សិន (ខល ឬភុត) តែក្នុងគោលបំណងការពារហានិភ័យ។ ក្នុងការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអប់ហ្សិន ទាំងហានិភ័យជាក់លាក់ និងហានិភ័យទីផ្សារទូទៅ គ្រឹះស្ថានត្រូវគណនាប៉ូស៊ីសិនជាអប់ហ្សិន និងឧបករណ៍សាមីនៃអប់ហ្សិនទាំងនេះ (ប៉ូស៊ីសិនជាសាច់ប្រាក់ ឬប៉ូស៊ីសិនជាហ្វ័រវើដ) ដាច់ដោយឡែកពីប៉ូស៊ីសិនផ្សេងទៀត។ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអប់ហ្សិនមានសង្ខេបក្នុងតារាងខាងក្រោម៖

| ប៉ូស៊ីសិន | កាតព្វកិច្ចដើមទុន |
|---|---|
| ឡុងប៉ូស៊ីសិនជាសាច់ប្រាក់ និងឡុងភុតអប់ហ្សិន<br>ឬ<br>សតប៉ូស៊ីសិនជាសាច់ប្រាក់ និងឡុងខលអប់ហ្សិន | កាតព្វកិច្ចដើមទុន = តម្លៃទីផ្សារនៃមូលបត្រសាមីនៃអប់ហ្សិន X (កម្រិតហានិភ័យជាក់លាក់ + កម្រិតហានិភ័យទីផ្សារទូទៅ) – ចំណេញពីការអនុវត្តអប់ហ្សិន<br><br>*កំណត់ចំណាំ៖ ចំពោះអប់ហ្សិនដែលមានឥណប្រតិទានច្រើនជាង ៦ (ប្រាំមួយ) ខែ ចំណេញពីការអនុវត្តអប់ហ្សិន ត្រូវចាត់ទុកស្មើ 0 (សូន្យ)។* |

គ្រឹះស្ថានត្រូវបូកបញ្ចូលកាតព្វកិច្ចដើមទុនសម្រាប់អប់ហ្សិន បន្ថែមលើកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យពាក់ព័ន្ធ (ហានិភ័យអត្រាការប្រាក់ ហានិភ័យមូលបត្រកម្មសិទ្ធិ និងហានិភ័យអត្រាប្តូរប្រាក់)។ បន្ទាប់មក កាតព្វកិច្ចដើមទុនត្រូវគុណនឹងមេគុណថ្លឹងទៅតាមប្រភេទហានិភ័យ (១,៣០ សម្រាប់ហានិភ័យអាត្រាការប្រាក់ ៣,៥០ សម្រាប់ហានិភ័យមូលបត្រកម្មសិទ្ធិ និង ១,២០ សម្រាប់ហានិភ័យអត្រាប្តូរប្រាក់)។

ឧទាហរណ៍នៃការគណនាកាតព្វកិច្ចដើមទុនសម្រាប់អប់ហ្សិនមានកំណត់ក្នុង "សេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ"។

## ជំពូកទី ៤

## បញ្ញត្តិផ្សេងៗ

**ប្រការ ៣០.- វិធានការចំពោះការអនុវត្តមិនត្រឹមត្រូវ**

ក្នុងករណីដែលគ្រឹះស្ថានមិនអាចបង្ហាញពីការគណនាហានិភ័យទីផ្សារឱ្យបានត្រឹមត្រូវចំពោះប៉ូស៊ីសិនក្នុងបញ្ជិកាជួញដូររបស់គ្រឹះស្ថាន ធនាគារជាតិនៃកម្ពុជាអាចៈ

- កំណត់ចំនួនបន្ទុកដើមទុនសម្រាប់ហានិភ័យទីផ្សារ ឬ
- តម្រូវឱ្យគ្រឹះស្ថានបញ្ឈប់ទាំងស្រុង ឬផ្នែកណាមួយនៃសកម្មភាពជួញដូរ។

វិធានការខាងលើក៏នឹងត្រូវបានអនុវត្តចំពោះគ្រឹះស្ថានដែលកត់ត្រាសកម្មភាពជួញដូរមិនត្រឹមត្រូវ ដោយកត់ត្រាឧបករណ៍ហិរញ្ញវត្ថុក្នុងបញ្ជិកាជួញដូរទៅក្នុងបញ្ជិកាធនាគារ។

ធនាគារជាតិនៃកម្ពុជា អាចបញ្ឈប់វិធានការខាងលើក្នុងករណីគ្រឹះស្ថានអាចបង្ហាញសមត្ថភាពក្នុងការគណនាហានិភ័យទីផ្សារបានត្រឹមត្រូវ។

**ប្រការ ៣១.- កាតព្វកិច្ចរាយការណ៍**

គ្រឹះស្ថានត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជានូវរបាយការណ៍ស្តីពី ប៉ូស៊ីសិនបញ្ជិកាជួញដូរប្រចាំឆមាស សម្រាប់គ្រប់រូបិយបណ្ណគិតជាមធ្យមរយៈពេល ៦ (ប្រាំមួយ) ខែ ចាប់ពីខែមករា រហូតដល់ខែមិថុនា និងពីខែកក្កដា រហូតដល់ខែធ្នូ យ៉ាងយូរបំផុតត្រឹមថ្ងៃទី១០ នៃខែមករា និងខែកក្កដារៀងគ្នា ដោយប្រើគំរូរបាយការណ៍ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១។

គ្រឹះស្ថានត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជានូវរបាយការណ៍ស្តីពី ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យទីផ្សាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ប្រចាំខែ នៅកម្រិតគ្រឹះស្ថាន យ៉ាងយូរបំផុតត្រឹមថ្ងៃទី១០នៃខែបន្ទាប់ និងប្រចាំត្រីមាស នៅកម្រិតគួបសរុប(ប្រសិនបើមាន) យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែទីមួយនៃត្រីមាសបន្ទាប់ ដោយប្រើគំរូរបាយការណ៍ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២។

## ជំពូកទី ៥

## ទណ្ឌកម្ម និងពិន័យ

**ប្រការ ៣២.- ទណ្ឌកម្មខាងវិន័យ**

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៣៣.- ពិន័យអន្តរការណ៍**

បន្ថែមលើទណ្ឌកម្មខាងវិន័យ ធនាគារជាតិនៃកម្ពុជាអាចដាក់ពិន័យអន្តរការណ៍ដូចខាងក្រោមៈ

១. គ្រឹះស្ថានដែលមិនគោរពកាតព្វកិច្ចរាយការណ៍ដូចមានកំណត់ក្នុងប្រការ ៣១ នៃប្រកាសនេះ នឹងត្រូវទទួលរងពិន័យជាទឹកប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ១ (មួយ) ថ្ងៃ។

២. គ្រឹះស្ថានដែលល្មើសនឹងបញ្ញត្តិផ្សេងៗទៀតក្រៅពីចំណុច (១) នៃប្រការនេះ នឹងត្រូវទទួលរងពិន័យជាទឹកប្រាក់ចំនួន ៣.០០០.០០០ (បីលាន) រៀល ក្នុង ១ (មួយ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលធនាគារជាតិនៃកម្ពុជាអនុញ្ញាតឱ្យកែតម្រូវផុតកំណត់។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**ប្រការ ៣៤.- និរាករណ៍**

បទប្បញ្ញត្តិដែលត្រូវបានចាត់ទុកជានិរាករណ៍៖

- ប្រកាសលេខ ធ៧-០៧-១៣៤ ប្រ.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្ដីពី ការត្រួតពិនិត្យស្ថានភាពចំហសុទ្ធនៃរូបិយបណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ធ៧-០១២-១៨៤ ប្រ.ក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្ដីពី កម្រិតកំណត់នៃការកាន់កាប់ និងជួញដូរមូលបត្ររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- សេចក្ដីជូនដំណឹងលេខ ធ៧-០២០-៨៦៨ ឆ.ត ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្ដីពី ករណីលើកលែងកម្រិតកំណត់លើស្ថានភាពចំហសុទ្ធចំពោះរូបិយវត្ថុជាតិ និង
- រាល់លិខិតបទដ្ឋានដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ។

**ប្រការ ៣៥.- ការអនុវត្ត**

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកប្រតិបត្តិការ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៣៦.- ថ្ងៃមានប្រសិទ្ធភាព**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៤កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៤

**ទេសាភិបាល**

**ជា សិរី**

**កន្លែងទទួល៖**

- ដូចប្រការ ៣៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្ដីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្ដីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

## ឧបសម្ព័ន្ធ ១

## របាយការណ៍ ស្ដីពី ប៉ូស៊ីសិនបញ្ជិកាជួញដូរ

## សម្រាប់រយៈពេល ៦ខែ ពីខែមករា (កក្កដា)ឆ្នាំ.........ដល់ ខែមិថុនា (ធ្នូ) ឆ្នាំ.........

**Report on Trading Book Positions**

**For the 6-month period from January (July).........to June (December)..........**

| | មករា ដល់ មិថុនា (ឬ កក្កដា ដល់ ធ្នូ) January to June (or July to December) | | | | | | ជាមធ្យម Average |
|---|---|---|---|---|---|---|---|
| | មករា (កក្កដា) Jan. (Jul.) | កុម្ភៈ (សីហា) Feb. (Aug.) | មីនា (កញ្ញា) Mar. (Sep.) | មេសា (តុលា) Apr. (Oct.) | ឧសភា (វិច្ឆិកា) May (Nov.) | មិថុនា (ធ្នូ) Jun. (Dec.) | |
| ១. ប៉ូស៊ីសិនបញ្ជិកាជួញដូរសរុបនៅក្នុងតារាងតុល្យការ<br>1. Total on-balance sheet trading book positions | | | | | | | |
| *ប៉ូស៊ីសិនឧបករណ៍បំណុល*<br>*Debt instruments positions* | | | | | | | |
| *ប៉ូស៊ីសិនពីកិច្ចសន្យារីប៉ូ/រីវើសរីប៉ូ និង ប៉ូស៊ីសិនពីការខ្ចីខ្ចីនិងខ្ចីមូលបត្រ*<br>*Positions from repo/reverse repo and security borrowing and lending* | | | | | | | |
| *ប៉ូស៊ីសិនឧបករណ៍មូលបត្រកម្មសិទ្ធិ*<br>*Equity instruments positions* | | | | | | | |
| ២. ប្រតិបត្តិការឧបករណ៍និស្សន្ទសរុបក្នុងបញ្ជិកាជួញដូរ<br>2. Total derivative transactions in the trading book | | | | | | | |
| *ឧបករណ៍និស្សន្ទពាក់ព័ន្ធនឹងអត្រាការប្រាក់ និងឧបករណ៍បំណុល*<br>*Derivatives linked to interest rate and debt instruments* | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| *ឧបករណ៍និស្សន្ទពាក់ព័ន្ធនឹងមូលបត្រកម្មសិទ្ធិ និងសន្ទស្សន៍ភាគហ៊ុន*<br>*Derivatives linked to equity price and stock index* | | | | | | | |
| *ឧបករណ៍និស្សន្ទពាក់ព័ន្ធនឹងអត្រាប្តូរប្រាក់*<br>*Derivatives linked to foreign exchange* | | | | | | | |
| ៣. ប៉ូស៊ីសិនអត្រាប្តូរប្រាក់នៃគ្រប់រូបិយបណ្ណ<br>3. Foreign exchange positions of all currencies | | | | | | | |
| ៤. ប៉ូស៊ីសិនបញ្ជិកាជួញដូរសរុប (១+២+៣)<br>4. Total trading book positions (1+2+3) | | | | | | | |
| ៥. ទ្រព្យសកម្មសរុប<br>5. Total assets | | | | | | | |
| ៦. ភាគរយនៃប៉ូស៊ីសិនបញ្ជិកាជួញដូរ (៤÷៥)<br>6. Percentage of trading book positions (4÷5) | | | | | | | |

# ឧបសម្ព័ន្ធ ២

## របាយការណ៍ ស្ដីពី ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យទីផ្សារ របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

**Report on Risk-weighted Assets (RWA) for Market Risk in Deposit-taking Banks and Financial Institutions**

| | |
|---|---|
| លេខសម្គាល់របាយការណ៍<br>Report ID | |
| ជំនាន់របាយការណ៍<br>Report Version | |
| កាលបរិច្ឆេទ<br>As at | |
| ឈ្មោះគ្រឹះស្ថាន<br>Institution's Name | |
| អត្រាប្ដូរប្រាក់ក្នុង ១ ដុល្លារអាមេរិក = X រៀល<br>Exchange Rate 1 USD = X Riel | |
| ឯកតាគិតជាលានរៀល<br>In million Riels | |

| | |
|---|---|
| **១.កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាការប្រាក់**<br>**1. Capital requirement for interest rate risk** | |
| ១.១ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យជាក់លាក់<br>1.1 Capital requirement for specific risk | |
| ១.២ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារទូទៅ<br>1.2 Capital requirement for general market risk | |
| ១.៣ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអប់ហ្សិនពីឧបករណ៍បំណុល<br>1.3 Capital requirement for option risks from debt instruments | |
| សរុបកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាការប្រាក់ (ក)<br>Total capital requirement for interest rate risk (A) | |
| បន្ទុកដើមទុនសម្រាប់ហានិភ័យអត្រាការប្រាក់ (I) = (ក) x ១,៣០<br>Total capital charge for interest rate risk (I) = (A) x 1.30 | |
| **២. កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យមូលបត្រកម្មសិទ្ធិ**<br>**2. Capital requirement for equity risk** | |
| ២.១ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យជាក់លាក់<br>2.1 Capital requirement for specific risk | |

| | |
|---|---|
| ២.២ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យទីផ្សារទូទៅ<br>2.2 Capital requirement for general market risk | |
| ២.៣ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអប់ហ្សិនពីឧបករណ៍មូលបត្រកម្មសិទ្ធិ<br>2.3 Capital requirement for option risks from equity instruments | |
| សរុបកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យមូលបត្រកម្មសិទ្ធិ (ខ)<br>Total capital requirement for equity risk (B) | |
| បន្ទុកដើមទុនសម្រាប់ហានិភ័យមូលបត្រកម្មសិទ្ធិ (II) = (ខ) x ៣,៥០<br>Total capital charge for equity risk (II) = (B) x 3.50 | |
| **៣.កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាប្តូរប្រាក់**<br>**3. Capital requirement for foreign exchange risk** | |
| ៣.១ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាប្តូរប្រាក់<br>3.1 Capital requirement for foreign exchange risk | |
| ៣.២ កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអប់ហ្សិនពីឧបករណ៍ហិរញ្ញវត្ថុពាក់ព័ន្ធនឹងអត្រាប្តូរប្រាក់<br>3.2 Capital requirement for option risks from foreign exchange instruments | |
| សរុបកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យអត្រាប្តូរប្រាក់ (គ)<br>Total capital requirement for foreign exchange risk (C) | |
| បន្ទុកដើមទុនសម្រាប់ហានិភ័យអត្រាប្តូរប្រាក់ (III) = (គ) x ១,២០<br>Total capital charge for foreign exchange risk (III) = (C) x 1.20 | |
| **បន្ទុកដើមទុនសម្រាប់ហានិភ័យទីផ្សារ** (IV) = (I)+(II)+(III)<br>**Total Capital Charge for Market Risk** (IV) = (I)+(II)+(III) | |
| ***ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យទីផ្សារ*** *= (IV) x* ***១២,៥០***<br>*RWA for Market Risk = (IV) x 12.50* | |

# ឧបសម្ព័ន្ធ ៣

## កម្រិតថ្លឹងហានិភ័យជាក់លាក់ចំពោះឧបករណ៍ពាក់ព័ន្ធនឹងអត្រាការប្រាក់

| ប្រភេទ | ចំណាត់ថ្នាក់ | កម្រិតថ្លឹងហានិភ័យជាក់លាក់ |
|---|---|---|
| មូលបត្របំណុលរដ្ឋ | - មូលបត្របោះផ្សាយ ឬធានាដោយរាជរដ្ឋាភិបាលកម្ពុជា<br>- មូលបត្របោះផ្សាយដោយធនាគារជាតិនៃកម្ពុជា | 0% |
| | ចំណាត់ថ្នាក់សមមូលនឹង AAA ដល់ AA- | 0% |
| | ចំណាត់ថ្នាក់សមមូលនឹង A+ ដល់ BBB- | ០,២៥% (ឥណប្រតិទាននៅសល់ ≤ ៦ខែ) |
| | | ១% (៦ខែ < ឥណប្រតិទាននៅសល់ ≤ ២៤ខែ) |
| | | ១,៦% (ឥណប្រតិទាននៅសល់ > ២៤ខែ) |
| | ចំណាត់ថ្នាក់សមមូលនឹង BB+ ដល់ B- | ៨% |
| | ចំណាត់ថ្នាក់សមមូល ក្រោម B- | ១២% |
| | មិនមានចំណាត់ថ្នាក់ | ៨% |
| មូលបត្របំណុលមានលក្ខណៈគ្រប់គ្រាន់ | ចំណាត់ថ្នាក់សមមូលនឹង AAA ដល់ BBB- | ០,២៥% (ឥណប្រតិទាននៅសល់ ≤ ៦ខែ) |
| | | ១% (៦ខែ < ឥណប្រតិទាននៅសល់ ≤ ២៤ខែ) |
| | | ១,៦% (ឥណប្រតិទាននៅសល់ > ២៤ខែ) |
| មូលបត្របំណុលផ្សេងៗ | ចំណាត់ថ្នាក់សមមូលនឹង BB+ ដល់ BB- | ៨% |
| | ចំណាត់ថ្នាក់សមមូល ក្រោម BB- | ១២% |
| | មិនមានចំណាត់ថ្នាក់ | ៨% |

# ឧបសម្ព័ន្ធ ៤

## តារាងសង្ខេបស្តីពីកាតព្វកិច្ចដើមទុនសម្រាប់ឧបករណ៍និស្សន្ទពាក់ព័ន្ធនឹងអត្រាការប្រាក់

| ឧបករណ៍ | ហានិភ័យជាក់លាក់ | ហានិភ័យទីផ្សារទូទៅ |
|---|---|---|
| **ប្រតិបត្តិការហ្យូឈឺរនៅលើទីផ្សារផ្លូវការ** | | |
| - មូលបត្របំណុលរដ្ឋ | មាន | មាន៖ ពីរប៉ូស៊ីសិន |
| - មូលបត្របំណុលសាជីវកម្ម | មាន | មាន៖ ពីរប៉ូស៊ីសិន |
| - សន្ទស្សន៍អត្រាការប្រាក់ (ឧទាហរណ៍៖ SOFR) | គ្មាន | មាន៖ ពីរប៉ូស៊ីសិន |
| **ប្រតិបត្តិការហ្វ័រវើដនៅលើទីផ្សារវិលងបញ្ជរ** | | |
| - មូលបត្របំណុលរដ្ឋ | មាន | មាន៖ ពីរប៉ូស៊ីសិន |
| - មូលបត្របំណុលសាជីវកម្ម | មាន | មាន៖ ពីរប៉ូស៊ីសិន |
| - សន្ទស្សន៍អត្រាការប្រាក់ | គ្មាន | មាន៖ ពីរប៉ូស៊ីសិន |
| **កិច្ចសន្យាហ្វ័រវើដអត្រាការប្រាក់, កិច្ចសន្យាស្វប** | គ្មាន | មាន៖ ពីរប៉ូស៊ីសិន |
| **កិច្ចសន្យាហ្វ័រវើដអត្រាប្តូរប្រាក់** | គ្មាន | មាន៖ ប៉ូស៊ីសិនមួយ សម្រាប់រូបិយបណ្ណមួយ |
| **ប្រតិបត្តិការអប់ហ្សិន** | | |
| - មូលបត្របំណុលរដ្ឋ | មាន | ប៉ូស៊ីសិនជាអប់ហ្សិននិង ប៉ូស៊ីសិននៃឧបករណ៍សាមី ត្រូវបានគណនាដាច់ដោយឡែកពីប៉ូស៊ីសិនដទៃទៀត នៅក្នុងបញ្ជិកាជួញដូរ។ |
| - មូលបត្របំណុលសាជីវកម្ម | មាន | |
| - សន្ទស្សន៍អត្រាការប្រាក់ | គ្មាន | |
| - កិច្ចសន្យាហ្វ័រវើដអត្រាការប្រាក់ និង កិច្ចសន្យាស្វប | គ្មាន | |

# ឧបសម្ព័ន្ធ ៥

## តារាងសង្ខេបស្តីពីភាគពួកកិច្ចដើមទុនសម្រាប់ឧបករណ៍និស្សន្ទមូលបត្រកម្មសិទ្ធិ

| ឧបករណ៍ | ហានិភ័យជាក់លាក់ | ហានិភ័យទីផ្សារទូទៅ |
|---|---|---|
| **ប្រតិបត្តិការហ្យូឈរនៅលើទីផ្សារផ្លូវការ និងលើទីផ្សារវិលជុំបញ្ជរ** | | មាន, ហានិភ័យដូចឧបករណ៍សាមី |
| - មូលបត្រកម្មសិទ្ធិ | មាន | |
| - សន្ទស្សន៍ | មាន | |
| **ប្រតិបត្តិការអប់ហ្សិន** | | ប៉ូស៊ីសិនជាអប់ហ្សិននិងប៉ូស៊ីសិននៃឧបករណ៍សាមី ត្រូវបានគណនាដាច់ដោយឡែកពីប៉ូស៊ីសិនដទៃទៀតនៅក្នុងបញ្ជិកាជួញដូរ។ |
| - មូលបត្រកម្មសិទ្ធិ | មាន | |
| - សន្ទស្សន៍ | មាន | |